**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**
សំណុំរឿងព្រហ្មទណ្ឌលេខ ១៤១
ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨
សាលក្រមលេខ ១១០/០៧ (គ)
ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តព្រះសីហនុ**

បានបើកសវនាការជាសាធារណៈនៅសាលជម្រះក្តីនៃសាលាដំបូងខេត្តព្រះសីហនុនាថ្ងៃអង្គារ ៦រោច ខែផល្គុន ឆ្នាំច សំរឹទ្ធស័ក ពុទ្ធសករាជ២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងខេត្តព្រះសីហនុ

**តំណាងអយ្យការ**

[redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី

**មេធាវីការពារសិទ្ធិជនជាប់ចោទ**

លោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទ

**ដើម្បីជំនុំជំរះលើ** លើសំណុំរឿងព្រហ្មទណ្ឌលេខ ១៤១ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ ឡើងវិញទៅនឹងបណ្តឹងទាស់របស់ឈ្មោះ [redacted] វាសនា ភេទប្រុស កើតឆ្នាំ១៩៨៣ ជាតិខ្មែរ ទីកន្លែងកំណើតភូមិកោះតាចិន ឃុំកំពង់ត្រាច ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ (ឃុំខ្លួនកាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩) ។

ជាប់ចោទពីបទ គំរាមកំហែងថានឹងសម្លាប់ដោយមានលក្ខខណ្ឌ ប្រព្រឹត្តនៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ បទល្មើសមានចែងឱ្យនិងផ្តន្ទាទោសតាមមាត្រា ២៣៤ នៃក្រមព្រហ្មទណ្ឌ។

**បានឃើញ**

-ដីកាសន្និដ្ឋានស្ថាពរលេខ ៤១២១ អ.ក/១៨ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

ការអនុវត្តទោសលើឈ្មោះ ពេជ្រ វាសនា ទេ ។
ថ្ងៃព្រហស្បតិ៍ ១៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
ខេត្តព្រះសីហនុ, ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៩
ក្រឡាបញ្ជី

-ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៥៧៣ ត.ព.រ/១៨ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

-សាលក្រមព្រហ្មទណ្ឌលេខ ៦៤/០៥ (គ) ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩។

-កំណត់ហេតុអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩។

-កំណត់ហេតុស្តីពីការជូនដំណឹងសាលក្រមកំបាំងមុខ របស់លោកតំណាងអយ្យការ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ ហើយត្រូវបានជនជាប់ចោទឈ្មោះ [redacted] វាសនា សុំប្តឹងទាស់លើសេចក្តីសម្រេចនៃសាលក្រមកំបាំងមុខលេខ ៦៤/០៥ (គ) ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩។

## អំពីខ្លឹមសារអង្គហេតុនៃការចោទប្រកាន់

កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង១១ថ្ងៃត្រង់ ឈ្មោះ [redacted] វាសនា បានទៅដល់ផ្ទះឈ្មោះ [redacted] ណាត និងប្រពន្ធឈ្មោះ [redacted] សុខលាង ដែលស្ថិតនៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយបានគំរាមថាឱ្យរើសវ៉ាន់ចេញពីផ្ទះនេះ បើមិនចេញទេឈ្មោះ [redacted] វាសនា និងដុតផ្ទះចោល ហើយថែមទាំងគំរាមបាញ់សម្លាប់ទាំងពីរនាក់ប្តីប្រពន្ធឱ្យស្លាប់ទៀតផង។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ [redacted] វាសនា បានឆ្លើយថា កាលពីមុនខ្លួនត្រូវបានមេរបស់ខ្លួនប្រើឱ្យទៅមើលដីនិងផ្ទះរបស់គាត់ ស្ថិតនៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ហើយបានដេញអ្នកដែលមករស់នៅលើដីរបស់មេខ្លួនពិតមែន តែខ្លួនមិនបានចាំថាខ្លួនបាននិយាយអ្វីខ្លះទេ នៅពេលនោះខ្លួនពុំមានកាំភ្លើងឡើយ។ ចាប់ពីពេលដេញពួកគេមក ខ្លួនពុំដឹងថា អ្នកដែលរស់នៅលើដីរបស់មេខ្លួន បានចេញ ឬ មិនចេញនោះទេ ។ កន្លងមកខ្លួនមិនដែលដឹងថាមានរឿងពួកគេប្តឹងខ្លួនទេ ព្រោះខ្លួនមិនដែលបានទទួលដីកាកោះរបស់តុលាការទេ។ ទើបតែក្នុងខែមីនា ឆ្នាំ២០១៩ នេះ ខ្លួនត្រូវបានសមត្ថកិច្ចប៉ូលិសមកចាប់ឃាត់រូបខ្លួន ទើបខ្លួនបានដឹងរឿងនេះ។ ខ្លួនជាតែកុងវេយន្តរបស់មេផង និងធ្វើជាអង្គរក្សផង។ សំណូមពរ សូមតុលាការមេត្តាបន្ធូបន្ថយទោសដល់ខ្លួនផង ។

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណាត ឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ (ឯកសារទី១៥/២) មានខ្លឹមសារដូចតទៅ: កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ១១ ថ្ងៃត្រង់ ស្ថិតក្នុងភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានមនុស្សមួយក្រុមមានប្រុសមានស្រី បានដើរសំដៅមកកន្លែងខ្លួនស្នាក់នៅ ខណៈនោះបុរសម្នាក់(ក្រោយមកទើបដឹងថាឈ្មោះ [redacted] វាសនា) បានស្រែកដាក់ខ្លួន និងប្រពន្ធរបស់ខ្លួន ឱ្យរើសវ៉ាន់ចេញពីផ្ទះ ជាមួយគ្នានេះគាត់បានប្រើពាក្យគំរាមមកលើពួកខ្លួនថា "បើមិនរើសវ៉ាន់ចេញពីដីរបស់អញទេ អញ

នឹងដុតផ្ទះនេះចោល ហើយបើមិនចេញទៀត អញនឹងបាញ់សម្លាប់ចោល។ ខណៈពេលនោះពួកខ្ញុំបាទពុំបានតបអ្វីជាមួយគាត់ទេ គឺពួកខ្ញុំបាទរត់ទៅផ្ទះអ្នកជិតខាងដើម្បីឱ្យគេជួយ ហើយក្រោយមកទៀតក្រុមមនុស្សទាំងអស់នោះក៏ត្រឡប់ទៅវិញអស់ទៅ។ សូមបញ្ជាក់បន្ថែមថា អំឡុងពេលដែលឈ្មោះ [redacted] វាសនា ប្រើពាក្យសម្តីគំរាមពួកខ្ញុំបាទនោះ គឺខ្ញុំបាទឃើញកាបូបដែលគាត់ស្ពាយមានកាំភ្លើងខ្លីមួយដើម ហើយពេលនោះក៏មានសាក្សីបានស្តាប់ឮផងដែរ។ ដីដែលពួកខ្ញុំបាទសង់ខ្ទមស្នាក់នៅនោះមិនមែនជាដីរបស់ពួកខ្ញុំបាទនោះទេ គឺដីនោះខ្ញុំបាទបានសុំម្ចាស់ដីគេដើម្បីសង់ខ្ទមស្នាក់នៅបណ្តោះអាសន្នតែប៉ុណ្ណោះ។ ខ្ញុំបាទសំណូមពរឱ្យតុលាការផ្តន្ទាទោសជនល្មើសឈ្មោះ [redacted] វាសនា តាមច្បាប់និងសុំទាមទារសំណងជម្ងឺចិត្តចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] ហៀត ឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ (ឯកសារទី១៧/៤) មានខ្លឹមសារដូចតទៅ: កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង១១និង០០នាទីព្រឹក ខ្ញុំបាទបានដើរទៅលេងផ្ទះបងប្អូននៅម្តុំកន្លែងកើតហេតុ ដែលស្ថិតនៅទីតាំងភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ហើយពេលដើរមកដល់កន្លែងកើតហេតុនោះស្រាប់តែឮសំលេងឈ្មោះ [redacted] វាសនា បានគំរាមសម្លាប់ទៅលើឈ្មោះ [redacted] សុខហេង និងប្តី ថាឱ្យចេញពីផ្ទះ បើមិនដូច្នេះគាត់នឹងបាញ់សម្លាប់ចោល និងបានប្រើពាក្យមិនសមរម្យជាច្រើនទៅលើជនរងគ្រោះ។ ខ្ញុំបាទបានឃើញកាំភ្លើងសៀតនៅនឹងចង្កេះរបស់ឈ្មោះ [redacted] វាសនា ប៉ុន្តែមិនដឹងម៉ាកអ្វីទេ។ បន្ទាប់មកខ្ញុំបាទក៏ដើរចេញទៅបាត់មិនដឹងថាមានរឿងអ្វីកើតឡើងបន្តទៀតនោះទេ។ ខ្ញុំបាទសូមជម្រាបតុលាការថា ខ្ញុំបាទមិនដែលមានជំម្លោះអ្វីពីមុនមកទេជាមួយឈ្មោះ [redacted] វាសនា។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] ធន ឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ (ឯកសារទី១៧/២) មានខ្លឹមសារដូចតទៅ: កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង១១និង០០នាទីព្រឹក ខ្ញុំបាទបានជិះម៉ូតូទៅលេងនៅម្តុំកន្លែងកើតហេតុដែលស្ថិតនៅទីតាំងភូមិ៦ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ហើយពេលជិះមកដល់កន្លែងកើតហេតុនោះ ស្រាប់តែឃើញមនុស្សជាច្រើនឈរជុំគ្នា ខ្ញុំបាទក៏បានឈប់ចុះមើលហើយបានឃើញឈ្មោះ [redacted] វាសនា បានគំរាមសម្លាប់ទៅលើឈ្មោះ [redacted] សុខលាង និងប្តី ថាឱ្យរើផរ៉ាន់ចេញពីផ្ទះបើមិនដូច្នេះគាត់នឹងបាញ់សម្លាប់ចោល។ ខ្ញុំបាទបានឃើញកាំភ្លើងសៀតនៅនឹងចង្កេះរបស់ឈ្មោះ [redacted] វាសនា ប៉ុន្តែមិនដឹងម៉ាកអ្វីទេ។ បន្ទាប់មកខ្ញុំបាទក៏ដើរចេញទៅបាត់មិនដឹងថាមានរឿងអ្វីកើតឡើងបន្តទៀតនោះទេ។ ចំពោះឈ្មោះ [redacted] វាសនា ខ្ញុំបាទមិនដែលស្គាល់គាត់ពីមុនមកទេ ប៉ុន្តែក្រោយកើតហេតុទើបអ្នកភូមិនៅម្តុំនោះប្រាប់ខ្ញុំបាទថា បុរសដែលស្រែកគំរាមឈ្មោះ [redacted] សុខលាង និងប្តីនោះគឺឈ្មោះ ពេជ្រ វាសនា ។ ទន្ទឹមគ្នានេះ ចំពោះរូបថតបុរសម្នាក់ដែលមានក្នុងកាតកងយោធពលខេមរភូមិន្ទ

ដែលតុលាការបានលើកយកមកបង្ហាញខ្លួននេះ គឺមានភិនភាគដូចបុរសដែលខ្លួនបានឃើញនៅកន្លែងកើតហេតុប្រាកដមែន បុរសនោះគឺឈ្មោះ [redacted] វាសនា ។

លោកតំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្នុងរឿងព្រហ្មទណ្ឌលេខ ១៤១ ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១៨ ហើយបានចេញសាលក្រមលេខ ៦៤/០៥ (គ) ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ ២០១៩ ដែលបានផ្តន្ទាទោសរួចហើយ នៅពេលនេះតំណាងអយ្យការសុំតម្កល់សាលក្រមលេខ ៦៤/០៥ (គ) ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ ដដែល។

លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនឈ្មោះ [redacted] វាសនា បានឆ្លើយសារភាពជូនអង្គសវនាការរួចហើយ ប៉ុន្តែពេលដែលគាត់បានទទួលបញ្ជាពីមេរបស់គាត់ ឱ្យទៅពិនិត្យមើលដីនិងផ្ទះរបស់មេគាត់ ហើយការទទួលបញ្ជាពីមេរបស់គាត់នេះពុំមានលាយលក្ខអក្សរអ្វីទេ ទើបគាត់ទៅប្រព្រឹត្តបទល្មើសមិនដឹងខ្លួន ទោះបីជាយ៉ាងណានៅពេលនេះកូនក្តីខ្លួនបានទទួលស្គាល់កំហុសរបស់គាត់ ដូច្នេះសូមឱ្យចៅក្រមជំនុំជម្រះផ្តល់ស្ថានសម្រាលទោសតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ដោយក្តីអនុគ្រោះ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់មេធាវីជនជាប់ចោទ

ក្រោយពីបានពិនិត្យឯកសារផ្សេងៗក្នុងសំណុំរឿង

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-បណ្តឹងទាស់របស់ជនជាប់ចោទនៅក្នុងកំណត់ហេតុឱ្យដំណឹងអំពីសាលក្រមកំបាំងមុខ លេខ ៦៤/០៥ (គ) ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ មានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ដែលអាចឱ្យតុលាការលើកយកមកជំនុំជម្រះសារជាថ្មីបាន។

-នៅក្នុងសាលក្រមព្រហ្មទណ្ឌលេខ ៦៤/០៥ (គ) ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ ដែលបានជំនុំជម្រះនិងសម្រេចផ្តន្ទាទោសកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វាសនា ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ។ ប៉ុន្តែក្រោយពីបានចេញសាលក្រមរួចមក ជនជាប់ចោទត្រូវបានចាប់ខ្លួនយកមកបង្ហាញខ្លួននៅចំពោះមុខតុលាការ ហើយក្នុងសាលសវនាការជនជាប់ចោទបានឆ្លើយ

សារភាព និងមានការភ្ញាក់រលឹកដឹងនូវកំហុសរបស់ខ្លួន គប្បីពិចារណាអំពីការព្យួរទោសធម្មតា ដើម្បីទុកឱកាសឱ្យជនជាប់ចោទកសាងខ្លួនជាប្រយោជន៍ដល់សង្គមវិញ។

-ចម្លើយរបស់ជនជាប់ចោទ និងអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងអំណានចម្លើយសាក្សី ឃើញថា មានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុយ៉ាងពិតប្រាកដមែន។ អំពើរបស់ជនជាប់ចោទគឺជាអំពើ គំរាមកំហែងថានឹងសម្លាប់ បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៣៤ នៃក្រមព្រហ្មទណ្ឌ។

-តាមសាលក្រមព្រហ្មទណ្ឌលេខ ៦៤/០៥ (គ) ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ ដែលបានសម្រេចផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំនោះ គប្បីតម្កល់ទុកជាបានការដដែល ប៉ុន្តែចំពោះមុខនេះ ជនជាប់ចោទបានសារភាពមានលក្ខណៈភ្ញាក់រលឹកដឹងកំហុសរបស់ខ្លួន ហើយព្យសនកម្មពុំបានបង្កឱ្យខូចខាតធ្ងន់ធ្ងរដល់ជនរងគ្រោះឡើយ ដូច្នេះដើម្បីទុកឱកាសឱ្យជនជាប់ចោទកសាងខ្លួនជាមនុស្សល្អ ដើម្បីរស់នៅក្នុងសង្គមវិញ គប្បីកែប្រែការផ្តន្ទាទោសជនជាប់ចោទពីការដាក់ពន្ធនាគារកំណត់ ១ឆ្នាំ មកជា ដាក់ពន្ធនាគារ ១(មួយ) ឆ្នាំ តែអនុវត្តទោស៦ខែ ទោសនៅសល់ត្រូវព្យួរធម្មតា ។

-ជនជាប់ចោទដែលបានចូលមកឆ្លើយបំភ្លឺចំពោះមុខតុលាការបានឆ្លើយសារភាព មានភាពស៊ីសង្វាក់ទៅនឹងចម្លើយដើមបណ្តឹង ចម្លើយសាក្សី និងឯកសារផ្សេងៗទៀត អាចឱ្យតុលាការពិចារណាដល់ការព្យួរទោសចំពោះជនជាប់ចោទ តាមមាត្រា ១០៦ នៃក្រមព្រហ្មទណ្ឌ។

ផ្អែកលើការយល់ឃើញខាងលើឃើញថា មានកស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] វាសនា ភេទប្រុស កើតឆ្នាំ១៩៨៣ ជាតិខ្មែរ ទីកន្លែងកំណើតភូមិកោះតាចិន ឃុំកំពង់ត្រាច ស្រុកកំពង់ត្រាច ខេត្តកំពង់ស្ពឺ ទីលំនៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ គេចខ្លួន ។

ពីបទ គំរាមកំហែងថានឹងសម្លាប់ដោយមានលក្ខខណ្ឌ ប្រព្រឹត្តនៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ បទល្មើសមានចែងឱ្យនិងផ្តន្ទាទោសតាមមាត្រា ២៣៤ នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះសាលាដំបូងខេត្តព្រះសីហនុ**
**វិនិច្ឆ័យសេចក្តី៖**

១.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៤/០៥ (គ) ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ ជាបានការដដែល ប៉ុន្តែកែប្រែចំណុចលេខ ១ នៃការផ្តន្ទាទោសលើឈ្មោះ ពេជ្រ វាសនា ភេទប្រុស មានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់ ១ (មួយ) ឆ្នាំ ទៅជា ផ្តន្ទាទោសលើឈ្មោះ

[redacted] វាសនា ដាក់ពន្ធនាគារ ១(មួយ) ឆ្នាំ ដដែលតែអនុវត្តទោសចំនួន ៦ខែ ក្នុងពន្ធនាគារឯទោស នៅសល់ត្រូវព្យួរជម្នតា ។

ពីបទ  គំរាមកំហែងថានឹងសម្លាប់ដោយមានលក្ខខណ្ឌ  ប្រព្រឹត្តនៅភូមិ៦  សង្កាត់លេខ៤ ក្រុងព្រះសីហនុ  ខេត្តព្រះសីហនុ  កាលពីថ្ងៃទី២១  ខែកុម្ភៈ  ឆ្នាំ២០១៨  បទល្មើសមានចែងឱ្យនិង ផ្តន្ទាទោសតាមមាត្រា ២៣៤ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈថ្ងៃអង្គារ ៦រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ ។ ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍តាមច្បាប់៕

ក្រឡាបញ្ជី

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]

---

បានឃើញ
ថ្ងៃព្រហស្បតិ៍ ១៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២
ខេត្តព្រះសីហនុ, ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩
ចៅក្រមជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ១៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២
ខេត្តព្រះសីហនុ, ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner